# ចម្លាក់រឿងទេវកថានៅប្រាសាទព្រះវិហារ

ប្រាសាទព្រះវិហារ មានទីតាំងស្ថិតនៅឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលបានចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោកកាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ (ទីក្រុងកេបិច ប្រទេសកាណាដា)។ ចាប់ពីចុងស.វ.ទី១៩មក ប្រាសាទនេះ ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការសិក្សាស្រាវជ្រាវពីអ្នកសិក្សាជាតិនិងអន្តរជាតិជាច្រើនរូប ហើយគេសង្កេតឃើញថាអ្នកសិក្សានីមួយៗបានផ្តល់នូវសម្មតិកម្មផ្សេងៗគ្នាចំពោះអាយុកាលរបស់ប្រាសាទនេះ។ ក្នុងនោះ លោក Victorio Roveda យល់ថា ប្រាសាទនេះទំនងកសាងឡើងដោយប្រើប្រាស់រយៈពេលជាង ៣០០ឆ្នាំ ចាប់ផ្តើមពីរជ្ជកាលព្រះបាទយសោវរ្ម័នទី១ (គ.ស.៨៨៩-៩១០) ដល់រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ (គ.ស.១១១៣-១១៥០)[១] ហើយអ្នកស្រាវជ្រាវជាច្រើនទៀតជឿថា សំណង់ភាគច្រើននៃប្រាសាទព្រះវិហារកសាងក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១១១៣)។[២] ជាទូទៅ គេតែងបែងចែកប្លង់ស្ថាបត្យកម្មប្រាសាទព្រះវិហារជា ៥ ផ្នែកធំៗ (រាប់ពីកំពូលភ្នំមកក្រោម ឬពីត្បូងទៅជើង) ដែលរួមមាន គោបុរទី១ (តួប៉មគភ៌គ្រឹះ ថែវព័ទ្ធជុំវិញ និងតួប៉មពីរសងខាង) គោបុរទី២ (ភ្ជាប់ទៅគោបុរទី៣ដោយស្ពានហាលក្រាលពីថ្មភក់) គោបុរទី៣ (ព្រះរាជដំណាក់ ឬអាស្រម) គោបុរទី៤ (ក្បែរស្រះទឹក ហើយភ្ជាប់គ្នាទៅគោរបុរទី៥ដោយស្ពានហាលក្រាលពីថ្មភក់) និងគោបុរទី៥ (ទីលានបង្កាន់ដៃនាគ និងជណ្តើរឡើងមកកាន់ប្រាសាទ)។ ក្រៅអំពីប្លង់ដ៏ល្អវិសេសវិសាលនេះ នៅប្រាសាទព្រះវិហារសម្បូណ៌ទៅដោយចម្លាក់រឿងទេវកថាជាច្រើននៅតាមគោបុរនីមួយៗ។ ក្នុងអត្ថបទខ្លីនេះ យើងនឹងរៀបរាប់ដោយសង្ខេបអំពីចម្លាក់ទេវកថានានាដែលមាននៅប្រាសាទព្រះវិហារ។

នៅគោបុរទី១ មានចម្លាក់ទេវកថាដ៏សំខាន់មួយ គឺចម្លាក់ព្រះឥសូររាំ ដែលគេឆ្លាក់នៅលើហោជាងច្រកចូលគភ៌គ្រឹះប្រាសាទ។ ព្រះឥសូរ គឺជាអាទិទេពធំជាងគេនៅក្នុងព្រហ្មញ្ញសាសនា ហើយជាទេពដែលចូលចិត្តរាំយ៉ាងខ្លាំង ទើបព្រះអង្គមានព្រះនាមថា "សិវនាដរាជ" ប្រែថា "ស្តេចនៃរបាំ"។[៣] ជាទូទៅរបាំដែលព្រះឥសូររាំមានឈ្មោះថា "តាណ្ឌវ" ហើយមានចង្វាក់ខុសៗគ្នាជាច្រើន ដូចជា នាតាត, លលិដ, កដិសម និងតលស្បក្ខដិត។[៤] នៅក្នុងសិល្បៈខ្មែរ យើងឃើញការ

[១] Roveda 2000.

[២] Briggs 1949.

[៣] Bhattacharya 1957.

[៤] Ibid.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

បង្ហាញចម្លាក់ព្រះឥសូររាំជាច្រើនទម្រង់ ដូចជា ឥសូររាំបង្កើតលោក ឥសូររាំថែរក្សាលោក ឥសូររាំរំឭកពីការថែរក្សាលោក ឥសូររាំរបាំនៃសេចក្ដីស្លាប់ ឥសូររាំបំផ្លាញក្រុងទាំងបី ឥសូររាំក្នុងការលែងវិញ្ញាណ ។ល។ ដែលការរាំទាំងនេះគេអាចសង្ខេបមកដោយខ្លីថា ការរាំកម្ចាត់នូវសភាវៈអាក្រក់ និងបង្កើតនូវសភាវៈល្អ។ ដោយឡែក ចម្លាក់ព្រះឥសូររាំនៅគោបុរទី១នៃប្រាសាទព្រះវិហារ ស្ថិតក្នុងទម្រង់មានព្រះហស្ដចំនួនដប់ ដោយព្រះហស្ដមួយកាន់ត្រីសូល៍ ព្រះហស្ដពីរលើកប្រណម្យ ហើយទ្រង់ឈររាំដោយយកព្រះបាទទាំងពីរជាន់នៅលើក្បាលដំរីដែលនៅខាងក្រោម មានរូបចម្លាក់ព្រះកាល និងនៅព្រះបាទខាងឆ្វេងមានរូបតួអង្គម្នាក់កំពុងអង្គុយលុតជង្គង់លើកដៃប្រណម្យបែរព្រះភក្ត្រទៅរកព្រះឥសូរ។ លោក Victorio Roveda យល់ថា ចម្លាក់ព្រះឥសូររាំនៅប្រាសាទព្រះវិហារ អាចសំដៅត្រង់ឈុតដែលព្រះឥសូរសម្លាប់បិសាចមួយឈ្មោះថា **"គជសុរ"** (បិសាចដំរី) ដែលមានរូបរាងជាសត្វដំរី។[៥] អ្នកនាង គុយ ម៉ីចៀន យល់ថា ការបង្ហាញចម្លាក់ព្រះឥសូររាំនៅសំណង់គគ្រឹះនៃប្រាសាទព្រះវិហារ អាចចង់បង្ហាញអំពីការធ្វើបដិហារបស់ទេព នៅពេលយាងចុះពីភ្នំព្រះសុមេរមកកាន់ប្រាសាទដែលគេចាត់ទុកគឺជាទីស្ថានរបស់ទេព រួចទើបបែកចេញទៅកាន់ទិសទាំងបួន ព្រោះអ្នកនាងយល់ថានៅស្រុកឥណ្ឌាចម្លាក់ព្រះឥសូររាំ គឺជាចម្លាក់សម្រាប់ព្រះរាជាដែលគេច្រើនតែឆ្លាក់នៅតួប៉មសំខាន់ៗនៃប្រាសាទ។[៦] ម្យ៉ាងវិញទៀត ដោយសារមានភស្ដុតាងសិលាចារឹក (K.383) ដែលរៀបរាប់ថា ព្រាហ្មណ៍ម្នាក់ឈ្មោះ "ទិវាករបណ្ឌិត" បានថ្វាយអំណោយជាចម្លាក់ព្រះឥសូររាំធ្វើអំពីមាសមកកាន់ប្រាសាទព្រះវិហារ។[៧] សិលាចារឹកនេះចារនៅឆ្នាំ១១១៩ នៃគ្រឹស្តសករាជ ដែលត្រូវនឹងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ (គ.ស.១១១៣-១១៥០) ហើយព្រាហ្មណ៍ទិវាករបណ្ឌិតនេះទៀតសោត ក៏ត្រូវជាព្រះរាជគ្រូរបស់ព្រះបាទសូរ្យវរ្ម័នទី២ដូចគ្នា។ ទោះបីព្រាហ្មណ៍នេះបានថ្វាយចម្លាក់ព្រះឥសូររាំមកកាន់ប្រាសាទព្រះវិហារក៏ដោយ ក៏ចម្លាក់ថ្មដែលយើងបានរៀបរាប់ខាងលើ ទំនងមិនមានអាយុកាលស្ថិតនៅក្នុងពេលដំណាលគ្នាទេ ពោល គឺទំនងជាចម្លាក់ដែលឆ្លាក់តាំងពីរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១មកម្ល៉េះ (រូបលេខ១)។

ដោយឡែក ចំពោះគោរបុរទី២វិញ គឺមានតែចម្លាក់បង្ហាញអំពីទេពទោល ដូចជា ព្រះកុវេរ ចម្លាក់ព្រះឥន្ទ្រគង់នៅលើដំរី ពុំមានបង្ហាញជាសាច់រឿងទេវកថាវែងឆ្ងាយឡើយ។ ប៉ុន្តែ គោបុរទី៣ ចម្លាក់ទេវកថាជាច្រើនបានឆ្លាក់បង្ហាញនៅតាមផ្តែរទ្វារ និងហោជាង ជាពិសេសចម្លាក់បង្ហាញ

---

[៥] Roveda 2005.

[៦] គុយ ម៉ីចៀន ២០២២។

[៧] Coedès 1954.

អំពីឈុតជាច្រើនក្នុងរឿងក្រឹស្ណ និងរឿងទេវកថាដទៃទៀត ដូចជាការបង្ហាញរូបព្រះវិស្ណុគង់នៅលើគ្រុឌ ឧមាមហេស្វរ ព្រះយមគង់នៅលើក្របី ផ្តែរទ្វារមានចម្លាក់ព្រះរាម ព្រះល័ក្ស និងនាងសីតា ព្រមទាំងចម្លាក់ព្រះកុវេរផងដែរ។ ឈុតរឿងក្រឹស្ណនៅគោបុរទី៣ នេះបង្ហាញអំពីឈុតព្រះក្រឹស្ណសម្លាប់សេះកេសិន ក្រឹស្ណទ្រភ្នំគោវ៌ធន និងក្រឹស្ណសម្លាប់ក្របីកុវលយបិទ។ ត្រង់ឈុតព្រះក្រឹស្ណសម្លាប់សេះកេសិន មានរឿងដំណាលថា មានអសុរមួយឈ្មោះថា "កេសិន" បានប្រែកាយខ្លួនជាសេះមួយយ៉ាងធំដើម្បីតាមសម្លាប់ព្រះក្រឹស្ណនិងពលរាម (រូបលេខ២) ដែលក្នុងពេលប្រយុទ្ធគ្នា គេឃើញសេះកសិនបានដេញខាំនិងដេញទាត់ព្រះក្រឹស្ណ តែត្រូវព្រះក្រឹស្ណបានដេញទាត់ព្រះក្រឹស្ណ តែទ្រង់បានចាប់ជើងបិសាចនេះគ្រវីទៅឆ្ងាយ និងបានលូកដៃចូលទៅក្នុងមាត់ដែលធ្វើឱ្យសេះថប់ដង្ហើមស្លាប់[៨] មួយឈុតទៀតបង្ហាញអំពីព្រះក្រឹស្ណទ្រភ្នំគោវ៌ធន ដែលសាច់រឿងដំណាលថា "គ្រាមួយក្រឹស្ណបានញុះញង់មិនឱ្យក្មេងៗជាអ្នកគង្វាល និងអ្នកភូមិថ្វាយសំណែនដល់ព្រះឥន្ទ្រ ជាហេតុដែលធ្វើឱ្យព្រះឥន្ទ្រខ្ញាល់យ៉ាងខ្លាំងរហូតដល់បង្អុរភ្លៀងធ្លាក់ខ្លាំងក្នុងបំណងឱ្យជន់លិចលង់សត្វគង្វាល និងអ្នកភូមិ ហើយពេលនោះព្រះក្រឹស្ណក៏ប្រែកាយរូបជាទៅជាមនុស្សធំលើកភ្នំគោវ៌ធនយកមកបាំងទឹកភ្លៀងរបស់ព្រះឥន្ទ្រនិងការពារក្មេងគង្វាល និងអ្នកភូមិ (រូបលេខ៣)។ មួយឈុតទៀតនៃព្រះក្រឹស្ណសម្លាប់ក្របីកុវលយបិទ ដែលនិទានថា "មានអសុរមួយបានប្រែក្រាយក្រឡាទៅជសត្វដំរីមួយយ៉ាងធំឈ្មោះថា កុវលយបិទ បានដេញតាមសម្លាប់ព្រះក្រឹស្ណ។ តាមការបញ្ជារបស់ស្តេចកម្ស ហើយក្នុងពេលនោះព្រះក្រឹស្ណបានចាប់បង្វិល និងកាច់ភ្លុកដំរីកុវលយបិទចោល[៩]" (រូបលេខ៤)។ ក្រៅអំពីចម្លាក់រឿងព្រះក្រឹស្ណមានចម្លាក់មួយសំខាន់ឆ្លាក់នៅចំកណ្តាលផ្តែរ គឺចម្លាក់បង្ហាញអំពីឈុតមួយនៃរឿងមហាភារត ត្រង់ព្រះឥសូរ និងអជ៌ុនប្រយុទ្ធគ្នា (រូបលេខ៥) ដែលមានសាច់រឿងនិទានថា "នៅពេលអជ៌ុននិងគ្រួសារបាននិរទេសចូលទៅក្នុងព្រៃ អជ៌ុនបានផ្សងព្រេងចូលទៅក្នុងព្រៃបំណងចង់ជួបព្រះឥសូរ ដោយបានធ្វើសមាធិឱ្យមានកម្លាំងខ្លាំងក្លា។ នៅពេលនោះមានឥសីមួយឃើញដូច្នេះក៏មកទូលព្រះឥសូរ ហើយព្រះឥសូរក៏បានប្រែក្រឡាទៅជាព្រានព្រៃម្នាក់ឈ្មោះថា "គត៌"។ ក្នុងពេលមួយ មានខ្លាឃ្មុំមួយប្រុងនឹងលោតសង្គ្រប់ទៅលើអជ៌ុន ពេលនោះអជ៌ុនក៏ទាញព្រួញបាញ់ដំណាលគ្នាជាមួយព្រួញគត៌ដែរ។ អជ៌ុន និងគត៌ បានឈ្លោះប្រកែកគ្នារហូតដល់ផ្ទុះការប្រយុទ្ធគ្នាឡើង។ ភ្លាមនោះ អជ៌ុនក៏បាននឹកគិតដល់ព្រះឥសូរឱ្យជួយខ្លួន ដោយបំពាក់កម្រងផ្កាលើព្រះសិររបស់ព្រះឥសូរ ស្រាប់តែមានកម្រងផ្កាបំពាក់លើព្រះសិរ

[៨] Roveda 2005.

[៩] Roveda 2005.

*របស់ព្រានគត់  ទើបអជ៌ុនដឹងថាគត់ជាព្រះឥសូរ។  ព្រះឥសូរមើលឃើញថាអជ៌ុនមានភាពស្មោះត្រង់ ក៏ប្រទានអាវុធទិព្វមួយដល់អជ៌ុន។*[១០]

ចុងក្រោយ គឺចម្លាក់ទេវកថាដ៏សំខាន់ៗនៅគោបុរទី៤ ដែលមានដូចជា ចម្លាក់កូរសមុទ្រទឹកដោះនៅលើហោជាង (រូបលេខ២៦) ចម្លាក់ព្រះវិស្ណុផ្ទុំរង់ចាំបង្កើតលោកនៅលើផ្ដែរ (រូបលេខ២៧) ចម្លាក់ព្រះក្រឹស្ណហែកនាគកលិយ និងចម្លាក់បង្ហាញអំពីព្រះកុវេរជាច្រើនផ្ទាំង (រូបលេខ២៨)។ ចំពោះរឿងកូរសមុទ្រទឹកដោះ មាននិទានដូចតទៅៈ "*ការកូរសមុទ្រទឹកដោះ គឺដើម្បីយកទឹកអម្រឹត និងជាការដណ្ដើមឧត្តមភាពរវាងពួកទេព និងពួកអសុរ។ ដំណើរការនៃការកូរសមុទ្រទឹកដោះប្រព្រឹត្តទៅរយៈកាលជាច្រើនពាន់ឆ្នាំ ទើបមានចេញទេព និងវត្ថុសក្តិសិទ្ធិនានាដូចជា ទេពអប្សរ សេះឧច្ចៃយស្វរ ដំរីក្បាលបីឰរាវត ព្រះនាងលក្ស្មី វារុនី (ទេពធីតាសុរា) ដើមបរីជាត  ធន្វន្តរិៈ (ជាអ្នកផ្សំថ្នាំ និងគ្រប់គ្រងទឹកអម្រឹត).... និងចុងក្រោយបង្អស់ គឺទឹកអម្រឹត ហើយថែរក្សាទុកដោយព្រះឥន្ទ្រ។ តាមដំណើររឿងពេលដែលធន្វន្តរី កាន់ថូទឹកអម្រឹតឡើងមកពួកទេព និងពួកអសុរក៏ឈប់កូរសមុទ្រទឹកដោះ ហើយច្បាំងគ្នាដណ្ដើមយកទឹកអម្រឹត។ ពួកអសុរជាភាគីដណ្ដើមបានទឹកអម្រឹត ប៉ុន្តែក៏មានវិវាទនឹងគ្នាឯង ត្បិតមិនដឹងថាឱ្យនរណាជាអ្នកថែរក្សា ឆ្លៀតឱកាសនោះ ព្រះ នារាយណ៍ក៏កាឡាខ្លួនជាស្រីស្អាតមោហិនី ទៅពន្វក់ពួកអសុរឱ្យស្រវឹង ហើយក៏យកទឹកអម្រឹតមកទុកនូវកន្លែងរបស់ទេព។ ពេលជាមួយនេះ មានអសុរមួយចូលមកបន្លំខ្លួនក្នុងជួរទេពលួចផឹកទឹកអម្រឹត ប៉ុន្តែព្រះចន្ទ្រ និងព្រះអាទិត្យឃើញហើយក៏ប្រាប់ទៅព្រះនារាយណ៍ ដើម្បីអន្តរាគមន៍។ ព្រះនារាយណ៍ក៏គ្រវែងកងចក្រទៅកាត់អសុរនោះដាច់ត្រឹមបំពង់កជាពីរកំណាត់នៅពេលដែលកំពុងផឹកទឹកអម្រឹត។*[១១] *ប៉ុន្តែដោយសារការជ្រៀបនូវទឹកអម្រឹតនោះធ្វើឱ្យផ្នែកទាំងពីរនោះមិនស្លាប់ (អមតៈ) ហើយត្រូវព្រាហ្មណ៍យកទៅទុកនៅស្ថានសួគ៌ក្លាយជាគព (ផ្កាយនព្វគ្រោះ)។ ផ្នែកខាងលើ(ក្បាល) ឱ្យឈ្មោះថា រាហូ និងមួយផ្នែកទៀត(ខ្លួន) ឈ្មោះកេតុ*[១២]។ ចំណែករឿងព្រះវិស្ណុផ្ទុំរងចាំបង្កើតលោកថ្មី អាចសង្ខេបមកថា " "*នៅពេលពិភពលោកទាំងមូលអាប់អួរ ការបំផ្លាញលោកចាស់ដើម្បីបង្កើតលោកថ្មីក៏ចាប់ផ្ដើមឡើងដែលសង្ឃឹមថាលោកទាំងមូលថ្មីនឹងមានសភាពប្រសើរជាងមុន។ ក្នុងពេលនោះ លោកទាំងមូលហ៊ុមព័ទ្ធដោយទឹកជំនន់យ៉ាងធំធេង ភ្លើងឆេះកល្បបំផ្លាញជីវិតសត្វនិងអ្វីទាំងអស់ដែលមាននៅលើលោក។ ព្រះ*

---

[១០] Roveda 2005.

[១១] Thomas 1999.

[១២] Thomas 1999.

អត្ថបទដោយៈ ម៉ង់ វ៉ាលី

វិស្ណុបានផ្ទុំលើនាគអនន្តដែលមានក្បាលសេស ហើយនៅពេលចុងបង្អស់នៃកល្ប ពិភពលោកក៏ប្រែក្លាយទៅជាទឹកសមុទ្រ ពេលនោះព្រះព្រហ្មក៏លេចចេញពីផ្ចិតព្រះវិស្ណុទ្រង់ដោយផ្កាឈូក ក្នុងតួនាទីជាអ្នកបង្កើតលោកថ្មី"។[១៣] រឿងទេវកថាចុងក្រោយ គឺរឿងព្រះក្រឹស្ណហែកនាគកាលិយ អាចសង្ខេបមកថា "ថ្ងៃមួយក្មេងៗគង្វាលបាននាំគ្នាលេងបាល់នៅមាត់ទន្លេកាលន្ទិ ពេលនោះព្រះក្រឹស្ណក៏មកលេងជាមួយក្មេងៗ ហើយក៏បានទាត់បាល់ចូលទៅក្នុងទឹកទន្លេ។ ក្មេងៗមានការខឹងសម្បារនឹងព្រះក្រឹស្ណយ៉ាងខ្លាំង ដ្បិតមិនមាននរណាហ៊ានចុះទៅក្នុងទន្លេនោះទេ ព្រោះគេដឹងថានៅក្នុងទន្លេមាននាគដែលមានពិសខ្លាំងរស់នៅ ដែលពីមុនមកធ្លាប់មានក្មេងៗ និងសត្វពាហនពុលស្លាប់។ ពេលនោះព្រះក្រឹស្ណក៏ចុះទៅក្នុងទន្លេរើសបាល់ ស្រាប់តែនាគកាលិយបានចេញមករុំព័ទ្ធព្រះកាយទ្រង់។ ទ្រង់ក៏បានលោតចេញពីការរុំព័ទ្ធ ហើយមកជិះពីលើនាគរាំរែកទន្ទ្រាំដើង និងចាប់ហែកនាគកាលិយនោះរហូតដល់ក្អួតឈាមស្ទើរនឹងស្លាប់ តែបានប្រពន្ធរបស់នាគចេញមកអង្វរកដល់ព្រះក្រឹស្ណកុំឱ្យសម្លាប់នាគកាលិយដែលជាប្ដីរបស់នាង។ ដោយនឹកអាណិតនឹងក្ដីអង្វរករបស់នាគញី ព្រះក្រឹស្ណក៏ទុកជីវិតឱ្យ តែបានបញ្ជាឱ្យនាគកាលិយនាំកូនចៅចេញពីទន្លេនេះឱ្យអស់ ចុះទៅនៅសមុទ្រវិញ។[១៤]

អ្វីដែលគួរកត់សម្គាល់នោះ នៅគោបុរទី៣ និងទី៤ គេនិយមឆ្លាក់រឿងព្រះក្រឹស្ណ។ អ្នកនាង កុយ ម៉ីចៀន យល់ថា វាជារឿងធម្មតាដែលសំណង់ប្រាសាទដែលឧទ្ទិសដល់ព្រះឥសូរសម្បូណ៌ដោយចម្លាក់ព្រះក្រឹស្ណ ដ្បិតនៅក្នុងគម្ពីរភគវត្តបុរាណ ជំពូកទី១១ ពន្យល់ថា ព្រះក្រឹស្ណគឺជាព្រះឥសូរក្នុងចំណោមពួកអ្នកគោរពបូជារុទ្រ។[១៥] ចំណែកឯ នៅគោបុរទី៤ គេនិយមឆ្លាក់រូបព្រះកុវេរវិញ ទំនងមកពីព្រះកុវេរមានតួនាទីជាទេពនៃទ្រព្យសម្បត្តិ និងភោគផលផ្នែកដំណាំកសិកម្ម ដែលជាទូទៅជាលោកបាលថែរក្សានៅទិសខាងជើង តែក្នុងគម្ពីររឿងមហាភារតពន្យល់ថា ព្រះកុវេរ និងព្រះឥន្ទ្រជាលោកបាលរួមគ្នាប្រចាំនៅទិសខាងកើត។[១៦]

ជារួមមក ចម្លាក់រឿងទេវកថានៅប្រាសាទព្រះវិហារ គេច្រើននិយមឆ្លាក់រឿងដែលទាក់ទងនឹងគំនិតដែលបង្កើតឱ្យមានភោគផល ដូចជារឿងកូរសមុទ្រទឹកដោះ ចម្លាក់ព្រះវិស្ណុផ្ទុំ ចម្លាក់ព្រះកុវេរ ជាដើម។ ក្រៅពីនេះ ក៏គេនិយមឆ្លាក់រឿងព្រះក្រឹស្ណ ដែលជាអវតារមួយនៃព្រះវិស្ណុ ហើយក៏

---

[១៣] Wilson 1896.

[១៤] Cornelia & Buitenen 1978; Wendy Doniger 1975.

[១៥] កុយ ម៉ីចៀន ២០២២។

[១៦] កុយ ម៉ីចៀន ២០២២។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ជាផ្នែកមួយនៃព្រះឥសូរដែរ តាមការពន្យល់របស់គម្ពីរកេតវត្តបុរាណ។ ម្យ៉ាងវិញទៀត ការបង្ហាញចម្លាក់ព្រះឥសូររាំនៅគោបុរទី១ ដែលជាគក់គ្រឹះសំខាន់នៃប្រាសាទព្រះវិហារ ស្ដែងឱ្យឃើញកាន់តែច្បាស់អំពីការចាត់ទុកប្រាសាទព្រះវិហារ គឺជាស្ថានរបស់ព្រះឥសូរ៕



រូបលេខ១៖ ចម្លាក់ព្រះឥសូររាំនៅលើហោជាង គក់គ្រឹះនៃគោបុរទី១



រូបលេខ២៖ ចម្លាក់ព្រះក្រឹស្ណសម្លាប់សេះកេសិន នៅគោបុរទី៣

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៣៖ ចម្លាក់ព្រះក្រឹស្ណទ្រភ្នំគោវធ៌ន នៅគោបុរទី៣



រូបលេខ២៤៖ ចម្លាក់ព្រះក្រឹស្ណសម្លាប់ដំរីកុវលយបិទ នៅគោបុរទី៣

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៥៖ ចម្លាក់បង្ហាញអំពីគត៌(ឥសូរ) និងអជ៌ន នៅគោបុរទី៣



រូបលេខ២៦៖ ចម្លាក់កូរសមុទ្រទឹកដោះ នៅគោបុរទី៤



រូបលេខ៧ៈ ចម្លាក់ព្រះវិស្ណុផ្ទុំរង់ចាំបង្កើតលោក នៅគោបុរទី៤



KHMER CIVILIZATION

រូបលេខ៨ៈ ចម្លាក់ព្រះកុវេរ នៅគោបុរទី៤

# ឯកសារយោង


**កុយ ម៉ីចៀន**

២០២២, "ប្រាសាទព្រះវិហារ", *សម្បត្តិបេតិកភណ្ឌពិភពលោកកម្ពុជា*, ភ្នំពេញ

**Briggs, Palmer B.**

1949, *The ancient Khmer empire,* American Philosophical Society.

**Coedès, George**

1954, *Inscription du Cambodge*, Vol VI, Hanoi.

**Dimmit, Cornelia & Buitenen, J.A.B**

1978, Classical Hindu Mythology, USA

**Roveda, Victorio**

2000, *Preah Vihear*, River Book, Bangkok, Thailand.

2005, *Image of the god*, River Book, Bangkok, Thailand.

**Thomas, Paul**

1999, *"Epics, Myths and Legends of India*", Treasure House of Books, Boombay.

**Wendy Doniger O'Flaherty**

1975, *Hindu myths*, Middlesex, England

**Wilson, H.H.**

1896, *A Pros of English Translation of VishnuPuranam,* Edited and Published by Manmatha Nath Dutt, M.A., M.R.A.S., Calcutta.


AMS អរិយធម៌ខ្មែរ KHMER CIVILIZATION